# កម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២ (ACCESS 2) ខេត្តរតនគិរី

## កម្មវិធី ACCESS 2 ជាការបន្តនៃការវិនិយោគទ្វេភាគីនៃប្រទេសអូស្ត្រាលី លើសមភាពយេនឌ័រ ការងារពិការភាព ការស្តារលទ្ធភាពពលកម្ម និងបរិយាបន្នសង្គមនៅកម្ពុជា។

## ព័ត៌មានសំខាន់ៗក្នុងខេត្តរតនគិរី

**២៦%** នៃស្ត្រីអាយុ១៥-៤៩ឆ្នាំ ដែលធ្លាប់មានប្តី ឬដៃគូស្និទស្នាលធ្លាប់រងអំពើហិង្សាលើរាងកាយ ផ្លូវភេទឬផ្លូវចិត្តប្រព្រឹត្តដោយប្តី/ដៃគូស្និទ្ធស្នាល។ អត្រាទូទាំងប្រទេសមានចំនួន២១%។ [១]

**២១,៦%** នៃប្រជាជនសរុបក្នុងខេត្តរតនគិរីដែលមានអាយុចាប់ពី៥ឆ្នាំឡើងទៅមានពិការភាពក្នុងទម្រង់ផ្សេងៗ(លំបាកខ្លះៗ លំបាកខ្លាំង និងមិនអាចធ្វើអ្វីកើត)។ អត្រាពិការភាពទូទាំងប្រទេសមានចំនួន ២៤,៤%។ [២]

**OPDs** អង្គការតំណាងជនមានពិការភាពមួយចំនួន (OPDs) អង្គការវេទិកាស្ត្រីមានពិការភាព និងអង្គការតំណាងជនជាតិដើមភាគតិច ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ការគាំទ្រចាំបាច់នានាដល់សមាជិករបស់គេនៅក្នុងខេត្តនេះ។

### ដៃគូរបស់កម្មវិធី ACCESS 2

កម្មវិធី ACCESS 2 នឹងបន្តធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និង សង្គមស៊ីវិល រួមទាំងអង្គការមិនមែនរដ្ឋាភិបាល បណ្តាញអង្គការតំណាងជនមានពិការភាព ក្រុមគាំទ្រស្ត្រី និងអង្គការតំណាងជនជាតិដើមភាគតិចដើម្បីចូលរួមអនុវត្តន៍ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW) និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព(NDSP) របស់រាជរដ្ឋាភិបាលកម្ពុជា ប្រកបដោយប្រសិទ្ធភាព។

[១] ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០២១-២០២២

[២] ជនមានពិការភាពនៅកម្ពុជា៖ របកគំហើញពីការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១៤ និង២០២១-២០២២

## ផ្នែកបរិយាបន្នពិការភាព

- ក្រុមប្រឹក្សាសកម្មភាពជនពិការខេត្ត(P-DAC)
- មន្ទីរសង្គមកិច្ច អតីយុទ្ធជន និងយុវនីតិសម្បទា ( មន្ទីរ ស.អ.យ. )
- មន្ទីរសុខាភិបាល
- អង្គការតំណាងជនមានពិការភាព (OPDs)
- អង្គការជនជាតិដើមភាគតិចដែលធ្វើការផ្នែកពិការភាព
- អង្គការជនពិការកម្ពុជា (CDPO)
- អង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍន៍ប្រកបដោយបរិយាបន្ន (PAfID)
- អង្គការ UNICEF

## ផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV)

- មន្ទីរកិច្ចការនារី
- មន្ទីរសុខាភិបាល
- តុលាការខេត្ត/ក្រុង
- ក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារថ្នាក់ខេត្ត និងស្រុក
- អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO)
- អង្គការ CARE កម្ពុជា
- អង្គការជនជាតិដើមភាគតិចដែលធ្វើការលើផ្នែក GBV
- អង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍន៍ប្រកបដោយបរិយាបន្ន (PAfID)

# សកម្មភាពចម្បងៗ

## អំពើហិង្សាទាក់ទងនឹងយេនឌ័រ

- ធ្វើឱ្យប្រសើរឡើងនូវការទទួលបានសេវាសម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាំងមាន និងមិនមានពិការភាព តាមរយៈការអភិវឌ្ឍន៍សមត្ថភាពដល់អ្នកឆ្លើយតបសេវាជួរមុខ។
- ពង្រឹងយន្តការសម្របសម្រួលជាពហុវិស័យឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) ។
- អនុវត្តសាកល្បងក្របខ័ណ្ឌ RESPECT WOMEN (អនុវត្តសាកល្បងយុទ្ធសាស្ត្រទាំង៧ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី)។
- បង្កើត និងដាក់ឱ្យដំណើការកន្លែងផ្តល់សេវាចម្រុះ។
- ពង្រឹងសេវាបញ្ជូនផ្នែក GBV ឱ្យកាន់តែរឹងមាំ។
- ផ្សព្វផ្សាយការយល់ដឹងពីច្បាប់ពាក់ព័ន្ធនឹង GBV និងសិទ្ធិជនមានពិការភាពនៅសហគមន៍។
- ផ្តល់សេវាផ្នែកច្បាប់ ប្រឹក្សាផ្លូវចិត្ត ព្យាបាលផ្លូវចិត្ត ផ្នែកសង្គម សុខភាព និងជម្រកសុវត្ថិភាព។
- ពង្រឹងការគ្រប់គ្រងករណីGBV និងការប្រើប្រាស់ប្រព័ន្ធឌីជីថលដើម្បីប្រមូល និងគ្រប់គ្រងទិន្នន័យ GBV។

## បរិយាបន្នពិការភាព

- គាំទ្រដល់ដំណើរការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការខេត្ត រួមទាំងការរៀបចំផែនការការងារ ថវិកា របាយការណ៍ និងការតាមដានការអនុវត្ត NDSP។
- បង្កើនសមត្ថភាពរបស់មន្ទីរស.អ.យ. ក្នុងការអនុវត្តកម្មវិធីអត្តសញ្ញាណកម្មជនមានពិការភាព និងការប្រើប្រាស់ទិន្នន័យពិការភាពពីប្រព័ន្ធគ្រប់គ្រងទិន្នន័យពិការភាព(DMIS)។
- ធ្វើការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ អង្គការតំណាងជនមានពិការភាព ឬអង្គការជនជាតិដើមភាគតិចដែលធ្វើការផ្នែកពិការភាពដើម្បីគាំទ្រសមាជិករបស់គេឱ្យទទួលបានសេវាសង្គមផ្សេងៗ និងកម្មវិធីជំនួយសង្គម។
- ពង្រឹងការងារផ្នែកអនាម័យ ទឹកស្អាតប្រកបដោយបរិយាបន្ននៅតាមមូលដ្ឋានសុខាភិបាល។
- បង្កើនការយល់ដឹងក្នុងចំណោមអ្នកពាក់ព័ន្ធអំពីសិទ្ធិជនមានពិការភាព។

## ការអភិវឌ្ឍន៍ជនជាតិដើមភាគតិច

- ពង្រឹងសេវាឆ្លើយតប និងកន្លែងសុវត្ថិភាពសម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។
- រៀបចំឱ្យមានជាកិច្ចពិភាក្សាគោលនយោបាយ និងការចែករំលែកព័ត៌មានអំពីតម្រូវការអន្តរវិស័យសម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ជនមានពិការភាព និងជនជាតិដើមភាគតិច។
- រួមចំណែកអនុវត្តសកម្មភាពផ្សេងៗទាក់ទឹងការផ្លាស់ប្តូរអាកប្បកិរិយារបស់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងពិការភាព។
- ចូលរួមពង្រឹងគុណភាពសេវាឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងពិការភាព។
- ធ្វើការស្រាវជ្រាវទៅលើ បទដ្ឋានសង្គមបិតាធិបតេយ្យនៅក្នុងសហគមន៍ជនជាតិដើមភាគតិច អំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។
- កសាងសមត្ថភាពដល់អង្គការតំណាងជនមានពិការភាព ដើម្បីដឹកនាំអនុវត្តសកម្មភាពផ្សេងៗទាក់ទងនឹងការលើកកម្ពស់ចំណេះដឹងបន្ថែមអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងផ្តល់ព័ត៌មានអំពីសេវាផ្សេងៗតាមរយៈសកម្មភាពគាំទ្រផ្លូវចិត្តសង្គមដល់ស្ត្រីមានពិការភាព។
- កសាងសមត្ថភាពដល់អង្គការតំណាងជនជាតិដើមភាគតិច ស្តីពីបរិយាបន្នសង្គម និងបរិយាបន្នពិការភាព។

សូមចូលទៅកាន់គេហទំព័រ
អាសយដ្ឋាន៖ អគារអានីណា ជាន់ទី៣ ផ្លូវ២៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទការិយាល័យ៖ (៨៥៥) ១២ ៨៧៦ ៥៤៩
សារអេឡិចត្រូនិក៖ info@access2cambodia.org
គេហទំព័រ៖ www.access2cambodia.org